ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ៦៩
ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣
សាលដីកា
លេខ : ៤៦៩ "ដ"
ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣

# សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោក ជាចៅក្រម

**ក្រឡាបញ្ជី**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទ:លោក** [redacted] ចាន់ថា (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៥៤ឆ្នាំ ជាតិខ្មែរ មុខរបរពាណិជ្ជករ ទីលំនៅសព្វថ្ងៃផ្ទះលេខ K9Eo ផ្លូវលេខ ១១១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

**មេធាវី :** លោកស្រី [redacted] តំណាងដោយអាណត្តិ

**ចុងចម្លើយ:លោក** [redacted] ហ៊ីម (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២០២A ផ្លូវលេខ ៣១០ សង្កាត់បឹងកេងកង ២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។





Scanned with CamScanner

**មេធាវី :** លោក [redacted] តំណាងដោយអាណត្តិ

**<u>អំពីវិវាទ</u>:** -ប្តឹងទាមទារប្រាក់ និង បែងចែកភាគហ៊ុនដាច់ពីគ្នា

## <u>អំពីអង្គហេតុ និង ចំណុចវិវាទ</u>

**ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ</u>**

ដើមចោទឈ្មោះ[redacted] ចាន់ថា អះអាងថា ខ្លួន និង ចុងចម្លើយឈ្មោះ [redacted] ហ៊ីម បានរកស៊ីចូលហ៊ុនគ្នាទិញលក់រថយន្ត ដោយបានទិញរថយន្តចំនួន ០៤គ្រឿងសម្រាប់លក់ សរុបជាទឹកប្រាក់ចំនួន ១០៥.៣០០ដុល្លា (ដប់ម៉ឺនប្រាំពាន់បីរយដុល្លាអាមេរិក) គឺ :

១-រថយន្តម៉ាក CAMRY XLE 2002 ពណ៌ទឹកប្រាក់ តម្លៃ ១៦.៥០០ដុល្លា( មួយម៉ឺនប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិក) ។

២-រថយន្តម៉ាក CAMRY XLE 2003 ពណ៌ស្គរ តម្លៃ ១៧.៣០០ដុល្លា( មួយម៉ឺនប្រាំពីរពាន់បីរយដុល្លាអាមេរិក) ។

៣-រថយន្តម៉ាក CAMRY HYBRID 2010 ពណ៌ខ្មៅ តម្លៃ ៣៦.៥០០ដុល្លា( បីម៉ឺនប្រាំមួយពាន់ប្រាំរយដុល្លាអាមេរិក) ។

៤-រថយន្តម៉ាក CAMRY XLE 2010 ពណ៌ស្វៃ តម្លៃ ៣៥.០០០ដុល្លា( បីម៉ឺនប្រាំពាន់ដុល្លាអាមេរិក) ។

ក្នុងនោះដើមចោទបានចេញប្រាក់ដើមចំនួន ៧២.៣០០ដុល្លា( ប្រាំពីរម៉ឺនពីរពាន់បីរយដុល្លាអាមេរិក) ហើយចុងចម្លើយចេញប្រាក់ដើមចំនួន ៣៣.០០០ដុល្លា( បីម៉ឺនបីពាន់ដុល្លាអាមេរិក) ។ ពេលលក់រថយន្តម៉ាក CAMRY HYBRID 2010 ពណ៌ខ្មៅ តម្លៃ ៣៦.៥០០ដុល្លា ចុងចម្លើយបានដកយកប្រាក់ដើមដែលខ្លួនបានចេញចំនួន ៣៣.០០០ដុល្លា គ្រប់ចំនួនរួចរាល់ហើយ ខ្លួនក៏បានទទួលស្គាល់ដែរ។ ដូច្នេះ រថយន្ត ០៣គ្រឿងទៀត ដែលនៅសល់ជារបស់ដើមចោទទាំងអស់ ។ក្រោយមកពេលលក់រថយន្តម៉ាក CAMRY XLE 2003ពណ៌ស្គរតម្លៃ១៧.៣០០ដុល្លា( មួយម៉ឺនប្រាំពីរពាន់បីរយដុល្លាអាមេរិក) បានចុងចម្លើយមិនព្រមប្រគល់ប្រាក់ថ្លៃលក់រថយន្តនេះមកអោយដើមចោទទេ ដែលការពិតប្រាក់ដើមថ្លៃរថយន្តនេះជាប្រាក់របស់ខ្ញុំ។

បណ្តឹងតបរបស់ចុងចម្លើយឈ្មោះ[redacted]ហ៊ីម អះអាងថា ខ្លួន និង ឈ្មោះ[redacted]ចាន់ថា មានទំនាក់ទំនងហ៊ុនគ្នារកស៊ីទិញលក់រថយន្ត ការរកស៊ីពុំដែលមានបញ្ហាជាមួយនឹងគ្នាទេ ដោយឡែកកាលពីថ្ងៃទី ២៣-១១-២០១០ យើងទាំងពីរនាក់បានទិញរថយន្តចំនួន ៤គ្រឿង ដោយចែកគ្នាចេញថ្លៃរថយន្តម្នាក់ ០២គ្រឿង( ដើម

63/5

បណ្ដឹងចេញថ្លៃ CAMRY XLE 2002 ពណ៌ទឹកប្រាក់ ១៦.៥០០ដុល្លា, CAMRY HYBRID 2010 ៣៦.៥០០ ដុល្លា ចុងចម្លើយចេញថ្លៃ CAMRY 2010 ពណ៌ស្វៃ ៣៥.០០០ដុល្លា, CAMRY XLE 2003 ពណ៌ស្វាវ ១៧.៣០០ ដុល្លា) ។ រថយន្តដែលបានលក់ ០៣គ្រឿងដំបូង គឺបានទូទាត់ប្រាក់ដើម និង ប្រាក់ចំណេញជាមួយគ្នាអស់ហើយ ចំពោះរថយន្តដែលលក់ចុងក្រោយគេ CAMRY XLE 2002 ពណ៌ប្រាក់ ១៦.៥០០ដុល្លា ដែលឈ្មោះ [redacted] ចាន់ថា បានលក់ចេញរួចរាល់ហើយ ប៉ុន្តែ [redacted] ចាន់ថា ពុំទាន់បានទូទាត់ប្រាក់ដើម និង ប្រាក់ចំណេញមកអោយខ្លួននៅឡើយទេ ដោយគាត់អះអាងថា រថយន្តនោះគាត់ជាអ្នកចេញប្រាក់សងគេ ប៉ុន្តែធាតុពិតឡានមួយគ្រឿងនេះ គឺខ្លួនជាអ្នកចេញសង ព្រោះភាគីហ៊ុនទាំងពីរបានព្រមព្រៀងគ្នាទូទាត់កាត់កងលុយគ្នា ដែលបានគិតបញ្ជីជាមួយគ្នា នៅថ្ងៃ ទី ០៧ ខែ ធ្នូ ឆ្នាំ ២០១០ ដោយគាត់កាត់កងឡាន CAMRY XLE 2002 ពណ៌ប្រាក់ ដាក់ជាកម្មសិទ្ធិរបស់ខ្ញុំ ជាអ្នកចេញប្រាក់សង ហើយមានបញ្ជាក់ឈ្មោះខ្ញុំជាអ្នកចេញសងថ្លៃឡាននេះក្នុងបញ្ជីជាលាយលក្ខ័អក្សរទាំងសង ខាង ហើយថ្លៃជួសជុលឡាននេះ ក៏ខ្ញុំជាអ្នកចេញសងថ្លៃជួសជុលទាំងស្រុងដែរ ។ អង្គហេតុមួយទៀតដែលទាក់ ទងនឹងរថយន្តម៉ាក TOYOTA HIGHLANDER ឆ្នាំផលិត ២០០២ ពណ៌ខ្មៅ មានលេខតួ JTHF 21A 720076057 លេខម៉ាស៊ីន IMD 1355363 គ្រដាសពន្ធជារថយន្តដែលខ្ញុំជាអ្នកចេញមុខទិញ ហើយចេញសោហ៊ុយជួសជុលដោយខ្លួនឯង ប៉ុន្តែឈ្មោះ [redacted] ចាន់ថា បែរជាយករថយន្តនេះទៅទុកក្នុងឃ្លាំងឡានទុកជាកម្មសិទ្ធិរបស់គាត់ទៅវិញ ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៩៥"ច" ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចៈ**

១-អោយចុងចម្លើយឈ្មោះ [redacted] ហ៊ឹម :

ក/សងប្រាក់ចំនួន ២២.៨៣៥(ពីរម៉ឺនពីរពាន់ប្រាំបីរយសាមសិបប្រាំ)ដុល្លាអាមេរិក និង

ខ/បង់ជម្ងឺចិត្តចំនួនស្មើនឹង ២.០០០(ពីរពាន់) ដុល្លាអាមេរិក ទៅដើមចោទឈ្មោះ [redacted] ចាន់ថា ។ ច្រានចោលការទាមទារលើសពីនេះ ។

២-ច្រានចោលការទាមទារក្នុងបណ្ដឹងតបរបស់ចុងចម្លើយ ។

៣-ច្រានចោលការសុំអោយប្រកាសអនុវត្តជាបណ្ដោះអាសន្នរបស់ដើមចោទ ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ និង ចុងចម្លើយទៅតាមភាគដែលចាញ់ក្ដី ។

*សាលក្រមនេះត្រូវបានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] ហ៊ឹម ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ ៣៤៦ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ត្រង់ចំណុចទី ១ (ក,ខ) និង*



Scanned with CamScanner

63
4

*ចំណុចទី ២ ទាំងមូល ។*

**បានឃើញសាលដីកាឧទ្ធរណ៍លេខ ២៤ ក្រ VI ៉វ៉ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍សំរេច:**

១-ទទួលបណ្តឹង ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់លោក [redacted] ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-លុបចោលចំណុចទី ១ (ក,ខ) និង ចំណុចទី ២ នៃសាលក្រមរដ្ឋប្បវេណីលេខ ៥៥(ច) ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១១ របស់ សាលាដំបូងរាជធានីភ្នំពេញចោលជាអសារបង់ និង សំរេចជាថ្មីដូចតទៅ :

-បង្គាប់អោយដើមចោទឈ្មោះ [redacted] ចាន់ថា សងប្រាក់ចំនួន ៧០០ដុល្លា( ប្រាំពីររយ)ដុល្លាអាមេរិក ទៅចុងចម្លើយឈ្មោះ [redacted] ហ៊ុម ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] ចាន់ថា ។

សាលដីកានេះប្រកាសជាសាធារណៈ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

*សាលដីកានេះត្រូវបានឈ្មោះ [redacted] ហ៊ុម ប្តឹងសាទុក្ខតាមបណ្តឹងលេខ ៣១៦ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ ត្រង់ចំណុចនៃសាលក្រមទាំងមូល ។*

**៤-<u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u>:**

ឈ្មោះ [redacted] ចាន់ថា ធ្វើសេចក្តីថ្លែងការណ៍ថា : ខ្លួនសុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ ព្រោះ [redacted] ហ៊ុម នៅជំពាក់ខ្លួនជាង ២ម៉ឺនដុល្លាទៀត តែសាលាឧទ្ធរណ៍បែរជាសំរេចអោយខ្លួនសងទៅ [redacted] ហ៊ុម ៧០០ ដុល្លាទៅវិញ ។

ក្នុងឡាន ៤គ្រឿង [redacted] ហ៊ុម បានចេញបានតែ ៣៣.០០០ដុល្លាប៉ុណ្ណោះ ក្រោយមកពេលលក់ឡាន CAMRY HYBRID 2010 បាន [redacted] ហ៊ុម បានដកយកដើមរបស់ខ្លួនរួចហើយ ដូច្នេះ [redacted] ហ៊ុម មិនមានសល់ប្រាក់ដើមទេ ។

បច្ចុប្បន្ននៅសល់ឡានកាមរីពណ៌ទឹកប្រាក់ តែនៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួន សរសេរថា [redacted] ចេញ តែតាមពិតគាត់មិនបានចេញទេ តែ [redacted] ហ៊ុម អាងលើកំណត់ហេតុនេះ បែរជាទាមទារថាជាប្រាក់ដើមរបស់គាត់ទៅវិញ ។

ឈ្មោះ [redacted] ហ៊ុម ធ្វើសេចក្តីថ្លែងការណ៍ថា : ខ្លួនសុំបដិសេធការលើកឡើងរបស់ឈ្មោះ [redacted] ចាន់ថា



Scanned with CamScanner

ព្រោះខ្លួនមិនទាន់បានដកដើមគ្រប់ចំនួនទេ គឺនៅខ្វះឡាន០១គ្រឿងទៀត។ គឺក្នុងឡាន ៤គ្រឿងនេះ ម្នាក់ចេញដើមឡានពីរ ខ្លួនចេញអស់ ៤៩.៥០០ដុល្លា។ ឡានតម្លៃ ១៦.៥០០ដុល្លា ខ្លួនជាអ្នកចេញ ដូចមានក្នុងកំណត់របស់ អ៊ុន ចាន់ថា សរសេរថា ហ៊ីម ចេញជាភស្តុតាងស្រាប់។

**សំណូមពរ :** ខ្លួនសុំទាមទារ ១១.៣០០ដុល្លា ជាប្រាក់ថ្លៃដើម។

**លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] ចាន់ថា ធ្វើសេចក្តីថ្លែងការណ៍** ថា : ក្នុងឡាន ៤គ្រឿង មានពីរគ្រឿងពុំមានវិវាទទេ។ កូនក្តីខ្លួនទាមទារប្រាក់ដើមពី [redacted] ហ៊ីម ១៧.៣០០ដុល្លា ដែល [redacted] ហ៊ីម បានលក់ តែ [redacted] ហ៊ីម ថា គាត់អោយលុះត្រាតែ អ៊ុន ចាន់ថា ប្រគល់ប្រាក់ដើម ១៦.៥០០ដុល្លា អោយគាត់ ដោយគាត់សំអាងលើកំណត់ដៃដែលចុះថា ប្រាក់ដើម ១៦.៥០០ដុល្លា ហ៊ីម ចេញ តែតាមពិតប្រាក់ដើមនេះ [redacted] ចាន់ថា ជាអ្នកចេញ ដូចមានលិខិតបញ្ជាក់របស់អ្នកលក់ថា បានទទួលប្រាក់ ១៦.៥០០ដុល្លា ពី អ៊ុន ចាន់ថា និង ៣៣.០០០ដុល្លា ពី ហ៊ីម។

**សំណូមពរ :** កូនក្តីខ្លួនសុំទាមទារប្រាក់ពី ហ៊ីម ២២.៨៣៥ដុល្លា និង សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងមូល។

**លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] ហ៊ីម ធ្វើសេចក្តីថ្លែងការណ៍ថា :** កូនក្តីខ្លួនចេញដើមតាមសែក ៣៣.០០០ដុល្លា និង ឡានកាមរី ២០០២ ១៦.៥០០ដុល្លា។ ចំណុចវិវាទ គឺឡាន Camry XLE 2002 តម្លៃ ១៦.៥០០ដុល្លាអាមេរិក ដែលសរសេរក្នុងកំណត់ដៃរបស់ [redacted] ចាន់ថា ថា ហ៊ីម ចេញ តែគាត់បែរជាបដិសេធថា សរសេរមែន តែជាក់ស្តែង [redacted] ចាន់ថា ជាអ្នកចេញ។ ការដែលសាលាឧទ្ធរណ៍សំរេចឱ្យសង ៧០០ដុល្លា គឺត្រឹមត្រូវហើយ ព្រោះថ្លៃដើមឡាន Camry XLE 2002 តម្លៃ ១៦.៥០០ដុល្លា +ថ្លៃជួសជុល ១.៥០០ដុល្លា= ១៨.០០០ដុល្លា ទូទាត់ជាមួយឡាន Camry XLE 2003 តម្លៃ ១៧.៣០០ដុល្លា ដែល អ៊ុន ចាន់ថា ចេញ ហើយកូនក្តីខ្លួនបានលក់ គឺឈ្មោះ [redacted] ចាន់ថា នៅជំពាក់កូនក្តីខ្លួន ៧០០ដុល្លាទៀត។

ដោយឡែកឡាន TOYOTA HIGHLANDER តម្លៃ ១៩.៩០០$ កូនក្តីខ្លួនសុំយកតែប្រាក់ដើមពាក់កណ្តាលចំនួន ៩.៩៥០$ +៧០០$=១០.៣៥០$ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីថ្លែងហេតុរបស់មេធាវី គូក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

63/2

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣១៦ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] ហ៊ីម និង បណ្តឹងសាទុក្ខលេខ ៩៩ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] ចាន់ថា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចលុបចោលចំណុចទី ១(ក, ខ) និង ចំណុចទី ២ នៃសាល ក្រមរដ្ឋប្បវេណីលេខ ៩៥ "ច" ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ និង សំរេច បង្គាប់អោយដើមចោទ [redacted] ចាន់ថា សងប្រាក់ ៧០០ដុល្លាអាមេរិក ទៅចុងចម្លើយឈ្មោះ [redacted] ហ៊ីម នោះពុំទាន់ មានមូលដ្ឋានគ្រប់គ្រាន់ទេ ពីព្រោះថា :

ក/រថយន្ត Camry XLE 2002 ពណ៌ទឹកប្រាក់តម្លៃ ១៦.៥០០ដុល្លាអាមេរិក ក្នុងសំអាងហេតុរបស់ សាលាឧទ្ធរណ៍ផ្ទុយគ្នា ដោយក្នុងចំណុចយល់ឃើញក្នុងត្រេទី ៣. ៤ សាលាឧទ្ធរណ៍កំណត់ថា ចុងចម្លើយមិនបាន ទិញរថយន្តនេះទេ ប៉ុន្តែផ្ទុយទៅវិញក្នុងត្រេទី ៦ សាលាឧទ្ធរណ៍បែរជាយល់ឃើញថា ពុំមានហេតុផលណាមួយ ថា ចុងចម្លើយមិនបានចេញប្រាក់ថ្លៃរថយន្តនេះ ដូចការអះអាងរបស់ដើមចោទទេ ។

ខ/ចំពោះរថយន្តម៉ាក Camry XLE ពណ៌ស្គរ តម្លៃ១៧.៥០០ដុល្លាអាមេរិក ដែលសាលាឧទ្ធរណ៍យល់ ឃើញថា ជាប្រាក់របស់ដើមចោទចេញ ហើយត្រូវបានចុងចម្លើយយកទៅលក់មានតម្លៃស្មើដើម ១៧.៣០០ដុល្លា អាមេរិក បែរជាសាលាឧទ្ធរណ៍យល់ឃើញថា ដើមចោទនៅជំពាក់ប្រាក់ចុងចម្លើយ ៧០០ដុល្លា វិញ ។ ដែលការ យល់ឃើញ និង សន្និដ្ឋានផ្ទុយគ្នា ។

គ/ចំពោះរថយន្ត TOYOTA Highlander តាមចម្លើយរបស់គូភាគីនៅចំពោះមុខតុលាការកំពូលថា មានហ៊ុនម្នាក់ពាក់កណ្តាល ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២៤ក្រVI "រ" ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ ទាស់នឹងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិ និ ច្ឆ័ យ សេ ច ក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣១៦ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] ហ៊ីម ។



Scanned with CamScanner

២-ទទួលបណ្ដឹងសាទុក្ខលេខ ៩៩ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] ចាន់ថា ។

៣-បដិសេធសាលដីការដ្ឋប្បវេណីលេខ ២៤ក្រVI"វ"ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៤-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៦៩ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៥-ប្រាក់ប្រដាប់ក្ដីជាន់តុលាការកំពូលជាបន្ទុករបស់ គូភាគី ។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈ និង ប្រកាស នៅថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣

ប្រធាន

[redacted]